# KINGDOM OF CAMBODIA

## NATION RELIGION KING

--------

**Statement on**

**Employer of Zhong Yin (Cambodia) B Textile didn't allow 50 people of local union leaders and members of C.CAWDU local at Zhong Yin (Cambodia) B Textile reinstate as The Arbitration Council Award 306/15 issued 30th December 2015.**

On January 18, 2016 at 6:30 am, three local union leaders and 47 members of C.CAWDU went to work at the Zhong Yin factory at their previous position. According to the AC Award 306/15 issued December 30, 2015 we had the legal right to be reinstated. But when we walked into the factory, Mr. Sruoch who is the security of the Zhong Yin factory, didn't allow us to return to our work. He said; "I'm sorry everyone, the company don't allow all of you back work. Admin Mr. Vibol told me to tell you all." We asked the security Mr. Sruoch; "Please tell admin Mr Vibol that the AC Award ordered that we will be returned to our work, and that's why we are here". The security replied "You can contact the admin if you wish to know". We continued asking Mr. Sruoch; "Who is the admin we can contact to?" The security, Mr. Sruoch replied "You can contact admin Mr. Vibol because he told me to not allow you all back into the factory". Next, we contacted Mr. Vibol's by phone on the following number; 098 883 628. We asked him; "Brother, we wish to go back to work as the AC Award 306/15 issued 30th December 2015 requested, but the security didn't allow us into the factory. He added that you told him to stop us when we will enter the factory. Why don't you allow us back to work?" . Admin Mr. Vibol, replied; "The company didn't allow all of you back to work. You can follow more processes if you wish to continue your demand". After that we finished talking with the admin and we returned to our home.

Kandal province, 18th January 2016

Reporter

Oeng Soy Try Tuon Nayleng Tren Choeurn

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កំណត់ហេតុ
## ស្តីពី
## និយោជកក្រុមហ៊ុន ស៊្បុងយិន (ខេមបូឌា) ប៊ី ធិកស្លាយ៍ មិនឲ្យថ្នាក់ដឹកនាំសហជីព និង សមាជិក សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ ចំនួន ៥០នាក់ ចូលធ្វើការតាម សេចក្តីបង្គាប់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ៣០៦/១៥ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៥

ឆ្នាំពីរពាន់ដប់ប្រាំមួយ ខែមករា ថ្ងៃទីដប់ប្រាំបី វេលាម៉ោង ប្រាំមួយ និង សាមសិបនាទីព្រឹក ថ្នាក់ដឹកនាំសហជីពចំនួន បីនាក់ និងសមាជិកសហជីពចំនួន សែសិបប្រាំពីរនាក់ បានមកចូលធ្វើការតាមតួនាទីនិងមុខងារដូចដើមវិញ តាមសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ៣០៦/១៥ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៥។ ពេលដែលពួកយើងខ្ញុំដើរចូលតាមទ្វារចូលក្រុមហ៊ុន ត្រូវបានសន្តិសុខ របស់ក្រុមហ៊ុន ឈ្មោះ ស្រួច ភេទប្រុស ហាមឃាត់មិនឲ្យពួកយើងខ្ញុំចូលធ្វើការទេ ដោយនិយាយថា “*សុំទោសអ្នកទាំងអស់គ្នាក្រុមហ៊ុនមិនឲ្យចូលធ្វើការងារទេ ព្រោះរដ្ឋបាលឈ្មោះ វិបុល បានប្រាប់ខ្ញុំថា មិនឲ្យអ្នកទាំងអស់គ្នាចូលធ្វើការងារទេ*”។ ភ្លាមនោះ ពួកយើងខ្ញុំបានប្រាប់សន្តិសុខឈ្មោះ ស្រួច ថា “*បងប្រាប់រដ្ឋបាលទៅថាពួកខ្ញុំមកនេះគឺមកចូលធ្វើការងារតាមសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលបានបង្គាប់ឲ្យពួកខ្ញុំចូលធ្វើការងារវិញ*”។ ស្រាប់សន្តិសុខឆ្លើយថា “*បើចង់ដឹងទំនាក់ទំនងទៅរដ្ឋបាលក្រុមហ៊ុនខ្លួនឯងទៅ*”។ ក្រោយមកពួកខ្ញុំក៏បានសួរបន្ថែមទៀតថា “*បើឲ្យពួកខ្ញុំទំនាក់ទំនងទៅរដ្ឋបាលតើរដ្ឋបាលមួយណា?*” សន្តិសុខឈ្មោះ ស្រួច ក៏បានឆ្លើយតបថា “*ទំនាក់ទំនងទៅរដ្ឋបាលឈ្មោះ វិបុល ទៅព្រោះគាត់ជាអ្នកប្រាប់ខ្ញុំថាមិនឲ្យអ្នកទាំងអស់គ្នាចូលធ្វើការ*”។ បន្ទាប់មកពួកយើងខ្ញុំក៏បានទំនាក់ទំនងតាមរយៈទូរស័ព្ទដៃទៅរដ្ឋបាលឈ្មោះ វិបុល ដែលមានលេខទូរស័ព្ទ (០៩៨ ៨៨ ៣៦ ២៨) ពេលដែលពួកខ្ញុំទំនាក់ទំនងទៅពួកខ្ញុំបានសួរថា “*បងឥឡូវពួកខ្ញុំមកចូលធ្វើការតាមសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលពេលដែលពួកខ្ញុំដើរចូលស្រាប់តែសន្តិសុខឃាត់ពួកខ្ញុំមិនឲ្យចូលធ្វើការ ដោយគាត់ប្រាប់ថា បងជាអ្នកប្រាប់គាត់មិនឲ្យពួកខ្ញុំចូលធ្វើការ ហេតុអ្វីបានជាមិនឲ្យពួកខ្ញុំចូលធ្វើការងារវិញ?*” រដ្ឋបាលឈ្មោះ វិបុល បានឆ្លើយតបវិញថា “*ក្រុមហ៊ុនមិនឲ្យចូលធ្វើការទេ បើចង់ទាមទារធ្វើតាមនីតិវិធីបន្តទៀតទៅ*”។ ក្រោយពីពួកខ្ញុំនិយាយជាមួយរដ្ឋបាលចប់ ពួកខ្ញុំក៏បាននាំគ្នាត្រឡប់មកផ្ទះវិញរៀងៗខ្លួន។

កណ្តាល ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦

អ្នកធ្វើកំណត់ហេតុ